**សំណួរ**

អ្វីទៅជាយុត្តាធិការសកល?

**ចម្លើយ**

ក្នុងពេលបច្ចុប្បន្ននេះ បទល្មើសព្រហ្មទណ្ឌ មានលក្ខណៈស្មុគស្មាញ ពាក់ព័ន្ធប្រទេសជាច្រើន។ ច្បាប់ព្រហ្មទណ្ឌជាតិ និង អន្តរជាតិ បានចែងបង្កើតយុត្តាធិការព្រហ្មទណ្ឌ ជាច្រើនប្រភេទ ដើម្បីបើកផ្លូវជូនតុលាការ វិន្និច្ឆ័យសេចក្តី។ យុត្តាធិការទាំងនោះ ផ្អែកតាមទីកន្លែង ដែលបទឧក្រិដ្ឋ ត្រូវបានប្រព្រឹត្តិ (ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ២០០៩ មានចែងអំពីយុត្តាធិការក្នុងជំពូកទី៣)។ ក្នុងចំណោមនោះ មានយុត្តាធិការមួយប្រភេទមានឈ្មោះថា យុត្តាធិការសកល។ តើអ្វីទៅជាយុត្តាធិការសកល?

វាជាយុត្តាធិការ ដែលតុលាការគ្រប់ប្រទេស អាចវិនិច្ឆ័យសេចក្តីលើបទល្មើសព្រហ្មទណ្ឌ ទោះបី បទល្មើសមិនកើតក្នុងប្រទេសខ្លួន ជនល្មើស ឬជនសង្ស័យ មិនមែនជាប្រជាពលរដ្ឋខ្លួនក្តី។ យុត្តាធិការប្រភេទនេះ សម្រាប់បទឧក្រិដ្ឋកម្ម*មួយចំនួនតូច* ក្រោមច្បាប់អន្តរជាតិ ដូចជា បទប្រល័យពូជសាសន៍ បទទារុណកម្ម ដែលផលវិបាកនៃអំពើ ធ្វើឲ្យមានផលវិបាកធ្ងន់ធ្ងរ រំជួលដល់មនុស្សទូទាំងពិភពលោក។ រដ្ឋទាំងអស់សុទ្ធតែជាជនរងគ្រោះនៃអំពើនេះ រួមគ្នាដើម្បីលុបបំបាត់ ឬបង្ការនិទណ្ឌភាព ជានាមិនឲ្យឧក្រិដ្ឋជនរួចខ្លួនពីសំណាញ់ច្បាប់។ ជាការឆ្លើយតប រដ្ឋមានកាតព្វកិច្ចចូលរួម កាត់សេចក្តីឬមិនអាចធ្វើបាន បញ្ជូនជនសង្ស័យទៅប្រទេសផ្សេង ដើម្បីទទួលនូវការវិនិច្ឆ័យសេចក្តី ប្រកបដោយយុត្តិធម៌។ មាត្រា ៧ នៃ អនុសញ្ញាឆ្នាំ ១៩៨៤ ស្តីពីការប្រឆាំងអំពើទារុណកម្ម ដែលកម្ពុជា ជាភាគីក្នុងឆ្នាំ ១៩៩២ ចែងអំពីប្រភេទយុត្តាធិការនេះ៖

" *ក្នុងដែនដី ក្រោមយុត្តាធិការរបស់ខ្លួន បុគ្គល ត្រូវបានចោទថាបានប្រព្រឹត្តិបទល្មើសណាមួយ កំណត់ក្នុងមាត្រា ៤ និងក្នុងករណីស្ថិតក្នុងមាត្រា ៥ ត្រូវបានរកឃើញ ប្រសិនមិនធ្វើបត្យាប័នជននោះទេ រដ្ឋភាគី ត្រូវបញ្ជូនសំណុំរឿងទៅអាជ្ញាធរមានសមត្ថកិច្ច ក្នុងគោលបំណងធ្វើការចោទប្រកាន់។* "

**Further readings**: 1. Roger O’Keefe, Universal Jurisdiction: Clarifying the Basic Concept, Journal of International Criminal Justice 2(2004), 735-760; 2. ICRC, universal jurisdiction over war crimes, file:///C:/Users/poozs/Downloads/universal-jurisdiction-icrc-eng.pdf; 3. FIDH, Universal Jurisdiction Annual Review, 2016.